# ឆទ្ទន្តជាតក




*ព្រះសាស្តាកាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុនីក្រមុំមួយរូប បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា* ***កិំ នុ សោចសិ*** *ដូច្នេះជាដើម ។*

*បានឮថា ភិក្ខុនីក្រមុំនោះជាកុលធីតាអ្នកក្រុងសាវត្ថី បានឃើញទោសក្នុងឃរាវាស ហើយបួសក្នុងព្រះសាសនា ។ ថ្ងៃមួយ នាងទៅស្តាប់ធម៌ជាមួយនឹងភិក្ខុនីទាំងឡាយ បានសម្លឹងមើលព្រះអត្តភាព ដែលប្រកបដោយរូបសម្បត្តិដ៏ឧត្តម ដែលបុណ្យមានប្រមាណមិនបានបង្កើតឡើង របស់ព្រះទសពល ដែលកំពុងប្រថាប់គង់សម្តែងធម៌ លើអលង្កតធម្មាសនៈ ហើយគិតថា កាលដែលយើងត្រាច់ទៅក្នុងភពសង្សារវដ្ត ធ្លាប់ជាបាទបរិចារិកា របស់ព្រះមហាបុរសនេះទេហ្ន៎ ។ ខណៈនោះ* ***ជាតិស្សរញាណ*** *(ញាណជាគ្រឿងរលឹកជាតិ) បានកើតថា ក្នុងកាលដែលព្រះអង្គកើតជាដំរីឆទ្ទន្ត យើងធ្លាប់ជាបាទបរិចារិកា របស់ព្រះមហាបុរសនេះ ។ លំដាប់នោះ កាលដែលភិក្ខុនីរលឹកឃើញដូច្នេះ បីតិបាមោជ្ជដ៏ធំបានកើតឡើងដល់នាង ។ ដោយកម្លាំងនៃបីតិ នាងភិក្ខុនីទើបសើចចេញមកដោយសម្លេងខ្លាំង រួចហើយនាង*

គិតទៀតថា ឈ្មោះថា បាទបរិចារិកា ដែលមានអធ្យាស្រ័យធ្វើជាប្រយោជន៍ដល់ស្វាមី មានតិច ដែលមានអធ្យាស្រ័យមិនជាប្រយោជន៍នោះ មានច្រើន តើយើង (ក្នុងកាលនោះ) មានអធ្យាស្រ័យជាប្រយោជន៍ដល់ព្រះមហាបុរសនេះដែរទេ (ក៏ឃើញថា) នាងមានអធ្យាស្រ័យមិនជាប្រយោជន៍ ។ នាងកាលរលឹកជាតិក៏ឃើញថា យើងដាក់ចិត្តដែលជាទោសបន្តិចបន្តួច បានបញ្ជូនព្រានឈ្មោះសោនុត្តរ ឲ្យយកព្រួញពិសបាញ់ស្តេចដំរីឆទ្ទន្ត ដែលមានប្រវែង ១២០ ហត្ថ ឲ្យអស់ជីវិត ។ គ្រានោះ សេចក្តីសោកក៏កើតឡើង ហឫទ័យនាងក៏ទៅជាក្តៅ កាលមិនអាចនឹងទប់សេចក្តីសោកបាន ក៏ស្រែកយំដោយសំឡេងដ៏ខ្លាំង ។

ព្រះសាស្តាឃើញភិក្ខុនីនោះហើយ ទ្រង់ធ្វើការញញឹមឲ្យប្រាកដ កាលភិក្ខុសង្ឃទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន អ្វីជាហេតុនៃការញញឹមរបស់ព្រះអង្គ ? ព្រះសម្ពុទ្ធត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុនីក្រមុំនេះ រលឹកទោសដែលបានធ្វើលើតថាគត ក្នុងកាលមុន ទើបស្រែកយំ ដូច្នេះហើយ ទ្រង់នាំអតីតនិទានមកថា

ក្នុងអតីតកាល មានដំរី ៨០០០ អាស្រ័យនៅនឹងស្រះឆទ្ទន្ត ក្នុងហិមវន្តប្រទេស ដំរី (ទាំងនោះ ) មានឫទ្ធិ អាចហោះទៅកាន់អាកាសបាន ។ ក្នុងគ្រានោះ ព្រះពោធិសត្វកើតជាកូនរបស់ដំរីដែលជាប្រធាន លោកមានសម្បុរសសុទ្ធ មានមាត់និងជើងក្រហម ។ ក្នុងកាលខាងក្រោយមក ព្រះពោធិសត្វចម្រើនវ័យធំហើយ មានកម្ពស់ ៨៨ ហត្ថ បណ្តោយ ១២០ ហត្ថ ដល់ព្រមដោយប្រមោយ ដែលប្រាកដដូចភួងប្រាក់ មានប្រវែង ៥៨ ហត្ថ ភ្លុកទាំងពីររបស់ព្រះពោធិសត្វនោះ វាស់ដោយជុំវិញ មានប្រមាណ ១៥ ហត្ថ ប្រវែង ៣០ ហត្ថ ដល់ព្រមដោយឆព្វណ្ណរង្សី (មានរស្មី ៦ ពណ៌) ។ ដំរីពោធិសត្វនោះ ក៏បានជាប្រធាននៃដំរីទាំង ៨០០០ លោកតែងបូជាព្រះបច្ចេកពុទ្ធ ៥០០ អង្គ ។ លោកមានអគ្គមហេសី ២ គឺ ចូឡសុភទ្ទា និង មហាសុភទ្ទា ។ ស្តេចដំរីមានដំរី ៨០០០ ជាបរិវារ រស់នៅនឹងកញ្ចនគុហា ។

ចំណែកស្រះឆទ្ទន្តនោះ ដោយចំណែកបណ្តោយ និងទទឹង មានប្រវែង ៥០ យោជន៍ ត្រង់ផ្ទៃ ១២ យោជន៍ដែលនៅកណ្តាលស្រះនោះ មិនមានសារាយ និងចកឡើយ មានទឹក

ដែលមានពណ៌ដូចគំនរកែវមណីតាំងនៅ, បន្ទាប់ពីនោះមក មានព្រៃចង្កុលណីសុទ្ធ ទំហំ ១ យោជន៍ ដុះព័ទ្ធជុំវិញទឹកនោះ, បន្ទាប់ពីនោះមក មានព្រៃឧប្បលខៀវសុទ្ធ ទំហំ ១ យោជន៍ ដុះបិតនៅឡោមព័ទ្ធព្រៃនោះ, បន្ទាប់ពីនោះ មានព្រៃឧប្បលក្រហម ឧប្បលស បទុមក្រហម បទុមស កុមុទ ទំហំ ១ យោជន៍ៗ ដុះបិតនៅឡោមព័ទ្ធខាងមុខព្រៃនោះៗ បន្តបន្ទាប់គ្នា ។ នៅបន្ទាប់ព្រៃទាំង ៧ នោះ មានព្រៃចម្រុះ ដែលលាយដោយព្រៃសារាយជាដើម ទំហំ ១ យោជន៍ ដុះបិតនៅឡោមព័ទ្ធព្រៃទាំងនោះ ។ បន្ទាប់មក មានព្រៃស្រូវសាលីក្រហម ទំហំ ១ យោជន៍ ដុះក្នុងទឹកជម្រៅត្រឹមចង្កេះដំរី, បន្ទាប់មក មានពួកវល្លិទឹកទាំងឡាយដ៏ដេរដាស លាយចម្រុះដោយផ្កាមានពណ៌ខៀវ ពណ៌លឿង ពណ៌ក្រហម និងពណ៌សដែលមានក្លិនក្រអូប ទំហំ ១ យោជន៍ ដុះនៅខាងចុងនៃទឹក ព្រោះហេតុដូច្នេះ ទើបមានព្រៃទាំងឡាយ ១០ ទំហំ ១ យោជន៍ ៗ បន្តបន្ទាប់គ្នា ដូច្នេះឯង ។ បន្ទាប់ពីព្រៃលិចទឹកនោះមក មានព្រៃសណ្ដែករាជមាសតូច និងសណ្ដែករាជមាសធំ, បន្ទាប់ពីនោះ មានព្រៃឪឡឹក ត្រឡាច ឃ្លោក ល្ពៅ, បន្ទាប់មក មានព្រៃអំពៅដែលមានដើមទំហំប៉ុនដើមស្លា, បន្ទាប់ពីនោះ មានព្រៃចេក ដែលមានផ្លែធំប៉ុនភ្លុកដំរី, បន្ទាប់ពីនោះមក មានព្រៃសាលៈ, បន្ទាប់ពីនោះ មានព្រៃខ្នុរដែលមានផ្លែប៉ុនក្អម, បន្ទាប់ពីនោះ មានព្រៃអម្ពិលផ្លែផ្អែម, បន្ទាប់មក មានព្រៃស្វាយ, បន្ទាប់មក មានព្រៃក្ទិដ្ឋ, បន្ទាប់មក មានព្រៃចម្រុះដ៏ធំ, បន្ទាប់មក មានព្រៃឫស្សី ទាំងអស់នេះជាសម្បត្តិធម្មជាតិរបស់ព្រៃហិមពាន្ត ក្នុងកាលនោះ ។ ចំណែកក្នុងគម្ពីរសំយុត្តដ្ឋកថា ក៏បានពោលសម្បត្តិដែលកំពុងប្រព្រឹត្តទៅ ក្នុងកាលឥឡូវនេះ ដូចគ្នា ។

មានភ្នំ ៧ បិតឡោមព័ទ្ធព្រៃឫស្សី ។ បណ្ដាភ្នំទាំង ៧ នោះ ភ្នំទី ១ រាប់ចាប់ពីចំណែកខាងក្រៅមក មានឈ្មោះថា ចូឡកាឡបព៌ត, ភ្នំទី ២ មានឈ្មោះថា មហាកាឡបព៌ត, បន្ទាប់មក ភ្នំទី ៣ មានឈ្មោះថា ឧទកបព៌ត, បន្ទាប់មក ភ្នំទី ៤ មានឈ្មោះថា ចន្ទិមបស្សបព៌ត, បន្ទាប់មក ភ្នំទី ៥ មានឈ្មោះថា សូរិយបស្សបព៌ត, បន្ទាប់មក ភ្នំទី ៦ មានឈ្មោះថា មណិ-បស្សបព៌ត និងភ្នំទី ៧ មានឈ្មោះថា សុវណ្ណបស្សបព៌ត ។ សុវណ្ណបស្សបព៌តនោះ មានកម្ពស់ ៧ យោជន៍ បិតនៅឡោមព័ទ្ធស្រះឆទ្ទន្ត (មើលទៅ) ហាក់ដូចជាកណ្ដាប់មាត់ស្រះ ។

នៅខាងក្នុងសុវណ្ណបស្សបព៌តនោះ មានពន្លឺពណ៌មាស ព្រោះតែពន្លឺដែលផ្សាយចេញពីសុវណ្ណបស្សបព៌ត បានធ្វើឲ្យស្រះឆទ្ទន្តភ្លឺ ហាក់ដូចជាពន្លឺព្រះអាទិត្យដ៏ស្រទន់ ដែលទើបតែនឹងរះ ។ បណ្តាភ្នំខាងក្រៅនោះ (រាប់ពីក្នុងចេញទៅក្រៅវិញ) គឺ ភ្នំទី ៦ កម្ពស់ ៦ យោជន៍, ភ្នំទី ៥ កម្ពស់ ៥ យោជន៍, ភ្នំទី ៤ កម្ពស់ ៤ យោជន៍, ភ្នំទី ៣ កម្ពស់ ៣ យោជន៍, ភ្នំទី ២ កម្ពស់ ២ យោជន៍, ភ្នំទី ១ កម្ពស់ ១ យោជន៍ ។

នៅនឹងជ្រុងទិសឦសាននៃស្រះឆទ្ទន្ត ដែលភ្នំទាំង ៧ព័ទ្ធជុំវិញនេះ មានដើមជ្រៃធំដុះតាំងនៅក្នុងឱកាសដែលទឹកនិងខ្យល់ប៉ះត្រូវគ្នា ។ ដើមជ្រៃនោះវាស់ដោយជុំវិញ មានប្រមាណ ៥ យោជន៍, មានកម្ពស់ ៧ យោជន៍, មានមែកសាខា ៤ ផ្សាយទៅក្នុងទិសទាំង ៤ មានប្រវែង ៦ យោជន៍, សូម្បីមែកដែលដុះទៅខាងលើ ក៏មានប្រវែង ៦ យោជន៍ដូចគ្នា ព្រោះហេតុដូច្នេះ បើវាស់ពីគល់ទៅដល់ចុង មានកម្ពស់ ១៣ យោជន៍, ពីចុងមែកម្ខាងទៅចុងមែកម្ខាងទៀតប្រវែង ១២ យោជន៍, ប្រដាប់ដោយឫសជ្រៃ ៨០០០ ជាដើមឈើធំខ្ពស់ត្រដែត ហាក់ដូចជាភ្នំកែវមណីត្រដោល ។ ចំណែកនៅទិសខាងលិចស្រះឆទ្ទន្ត នៅក្នុងសុវណ្ណបស្សបព៌តមានកញ្ចនគុហា ដែលមានទំហំ ១២ យោជន៍ ។ ពេលមានភ្លៀង ស្តេចដំរីឈ្មោះឆទ្ទន្ត ដែលមានដំរី ៨០០០ ជាបរិវារ មកអាស្រ័យនៅនឹងកញ្ចនគុហានោះឯង ។ ពេលក្តៅ ស្តេចដំរីមកឈរទទួលខ្យល់និងទឹក នៅរវាងឫសជ្រៃ ជិតគល់មហានិគ្រោធព្រឹក្ស ។

ថ្ងៃមួយ ដំរីកំលោះទាំងឡាយមកប្រាប់ស្តេចដំរីថា មហាសាលវ័នចេញផ្កាហើយ ។ ស្តេចដំរីនោះ មានបរិវារចោមរោម ទៅកាន់សាលវ័នដោយគិតថា យើងនឹងលេងសាលកីឡា ដូច្នេះទើបយកពោងត្រដុសដើមសាលព្រឹក្ស ដែលមានផ្ការីកស្គុះស្គាយ ។ គ្រានោះ នាងចូឡ-សុភទ្ទាឋិតនៅក្នុងទីប្រាសខ្យល់ ស្លឹកឈើចាស់ៗ ដែលលាយដោយកម្ទេចឈើស្ងួត និងអង្ក្រងក្រហម ធ្លាក់លើសរីរៈរបស់នាង ។ ចំណែកនាងមហាសុភទ្ទាឋិតនៅខាងក្រោមខ្យល់ លម្អងកេសរ និងស្លឹកស្រស់ៗ បានធ្លាក់មកលើសរីរៈរបស់នាង ។ នាងចូឡសុភទ្ទាចងពៀរនឹងព្រះមហាសត្វថា ស្តេចដំរីនេះពោយពាយលម្អិតផ្កាឈើ និងស្លឹកស្រស់ៗ លើភរិយាជាទី

ស្រឡាញ់របស់ខ្លួន និងពោយពាយស្អឹកឈើចាស់ ដែលលាយដោយឈើស្ងួត និងអង្រ្គង ក្រហម មកលើសរីរៈរបស់យើង យើងនឹងដឹងនូវកិច្ចដែលគប្បីធ្វើដល់ស្តេចដំរីនោះ ។

ខាងក្រោយមក ថ្ងៃមួយ ស្តេចដំរីព្រមទាំងបរិវារ ចុះស្រះឆទ្ទន្តដើម្បីមុជទឹក ។ ពេលនោះ ដំរីក្មេង ២ យកប្រមោយចាប់ដុំស្បូវរណ្តាស មកដុសកាយស្តេចដំរី បីដូចចំអើតបោសកំពូលភ្នំកៃលាស ។ កាលស្តេចដំរីនោះមុជហើយឡើងមក មេដំរីទាំងពីរ ក៏មុជបន្ត ។ កាលមុជហើយ ទើបឡើងមកឈរ ក្នុងសម្នាក់ព្រះមហាសត្វ ។ បន្ទាប់មក ដំរីទាំង ៨០០០ ក៏ចុះស្រះ នាំគ្នាលេងទឹក រួចនាំយកផ្កាអំពីស្រះ មកប្រដាប់តាក់តែងព្រះមហាសត្វ បីដូចជាប្រដាប់តាក់តែងស្តូបប្រាក់ ហើយទើបប្រដាប់តាក់តែងមេដំរីទាំងពីរជាខាងក្រោយ ។ ពេលនោះ មានដំរីមួយកាលត្រាច់ទៅក្នុងស្រះ បានបេះផ្កាបទុមដ៏ធំឈ្មោះសត្តុស្សៈ នាំមកថ្វាយព្រះមហាសត្វ ។ ស្តេចដំរីយកប្រមោយទទួលផ្កានោះ ហើយពោយពាយលម្អងលើពោង (របស់ខ្លួន) រួចក៏ឲ្យទៅនាងមហាសុភទ្ទាដែលជាភរិយាធំ ។ នាងចូឡសុភទ្ទាឃើញដូច្នោះ ក៏អាក់អន់ដោយគិតថា ស្តេចដំរីនេះ ឲ្យមហាបទុមឈ្មោះ**សត្តុស្សៈ** ដល់ភរិយាជាទីស្រឡាញ់របស់ខ្លួនប៉ុណ្ណោះ មិនឲ្យដល់យើង ដូច្នេះទើបចងពៀរនឹងព្រះមហាសត្វបន្ថែមទៀត ។

ថ្ងៃមួយ កាលព្រះពោធិសត្វរៀបចំចាត់ចែងផ្លែឈើដែលរសផ្អែម ក្រអៅឈូក និងបោក្ខរមធុ ថ្វាយព្រះបច្ចេកពុទ្ធ ៥០០ អង្គឲ្យឆាន់ នាងចូឡសុភទ្ទាក៏បានថ្វាយផលាផលដែលខ្លួនមាន ដល់ព្រះបច្ចេកពុទ្ធនោះដែរ ហើយតាំងសេចក្តីប្រាថ្នាថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំកាលចុតិអំពីអត្តភាពនេះទៅ សូមឲ្យកើតក្នុងត្រកូលមទ្ទរាជ ជារាជកញ្ញា មានឈ្មោះថា **សុភទ្ទា** កាលចម្រើនវ័យធំហើយ សូមឲ្យបានជាអគ្គមហេសីរបស់ព្រះរាជានគរពារាណសី ហើយបានជាទីស្រឡាញ់ពេញចិត្តរបស់ព្រះរាជានោះ នឹងអាចឲ្យព្រះរាជាធ្វើតាមសេចក្តីប្រាថ្នារបស់ខ្ញុំម្ចាស់ ប្រាប់ព្រះរាជានោះឲ្យបញ្ជូននាយព្រានមួយរូប ដែលអាចបាញ់ដំរីនេះដោយព្រួញពិសឲ្យស្លាប់ ហើយនាំយកភ្លុកទាំងគូ ដែលបញ្ចេញឆព្វណ្ណរង្សីមក។

ចាប់តាំងពីពេលនោះមក នាងចូឡសុភទ្ទាមិនកាន់យកអាហារ រហូតដល់ស្គមស្គាំង មិនយូរប៉ុន្មាន នាងក៏ធ្វើកាលកិរិយា ហើយបានកើតក្នុងផ្ទៃរាជអគ្គមហេសី ក្នុងដែនមទ្ទរដ្ឋ ពួកញាតិដាក់ឈ្មោះឲ្យនាងថា សុភទ្ទា ។ កាលនាងចម្រើនវ័យធំហើយ មាតាបិតាក៏បានថ្វាយដល់ស្តេចនគរពារាណសី ។ ព្រះនាងជាទីស្រឡាញ់ពេញព្រះហឫទ័យ របស់ព្រះរាជានោះ បានជាធំលើស្រ្តី ១៦០០០ នាក់ និងបានទូវជាតិស្សរញាណផងដែរ ។ ព្រះនាងសុភទ្ទាគិតថា សេចក្តីប្រាថ្នារបស់យើងបានសម្រេចហើយ ឥឡូវនេះ យើងនឹងឲ្យគេ ទៅនាំភ្លុកទាំងគូរបស់ដំរីនោះមក ។ បន្ទាប់មក ព្រះនាងធ្វើជាមានខ្លួនប្រឡាក់ដោយប្រេង ស្លៀកសំពត់សៅហ្មង សម្តែងអាការឈឺ ចូលក្នុងបន្ទប់ដ៏មានសិរី ដេកលើគ្រែតូចមួយ ។ ព្រះរាជា (យាងមកហើយ) សួរថា នាងសុភទ្ទានៅឯណា ? ទ្រង់បានស្តាប់ថា ព្រះនាងឈឺ ទើបយាងចូលក្នុងបន្ទប់នោះ ប្រថាប់គង់លើគ្រែតូច អង្អែលខ្នង ហើយត្រាស់គាថាទី ១ ថា

កឹំ នុ សោចសិនុច្ចង្គិ, បណ្ឌុសិ វរវណ្ណិនិ;
មិលាយសិ វិសាលក្ខិ, មាលាវ បរិមទ្ទិតា។

ម្នាលនាងសុភទ្ទា ជាស្រីមានអវយវៈដូចមាស មានសម្បុរលឿងខ្ចី មានសម្បុរដ៏ប្រសើរ ថ្វីក៏បានជានាងសោយសោក ម្នាលនាងមានភ្នែកពិសាល ថ្វីក៏បានជានាងស្រពោន ដូចផ្កាឈូកដែលគេច្របាច់ ។

ព្រះនាងសុភទ្ទាស្តាប់ពាក្យនោះហើយ ពោលគាថាថា

ទោហឡោ មេ មហារាជ, សុបិនន្តេនុបជ្ឈគា;
ន សោ សុលភរូបោវ, យាទិសោ មម ទោហឡោ។

បពិត្រមហារាជ ចំណង់ប្លែក កើតឡើងដល់ខ្ញុំម្ចាស់ ដោយការយល់សប្តិ តែចំណង់ប្លែករបស់ខ្ញុំម្ចាស់នោះ ហាក់ដូចជាមិនងាយរកបានទេ ។

ព្រះរាជាស្តាប់ពាក្យនោះហើយពោលគាថាថា

**យេ កេចិ មានុសា កាមា, ឥធ លោកម្ហិ នន្ទនេ;**
**សព្ពេ តេ បចុរា មយ្ហំ, អហំ តេ ទម្មិ ទោហឡំ។**

*កាមគុណទាំងឡាយណាមួយ ជារបស់មនុស្ស ក្នុងលោក ជាទីត្រេកអរនេះ កាមគុណទាំងអស់នោះ មានច្រើនសុទ្ធតែជារបស់យើង យើងនឹងឲ្យនូវចំណង់ប្លែកដល់នាង ។*

ព្រះទេវីស្តាប់ពាក្យនោះហើយ ពោលថា បពិត្រមហារាជ ចំណង់ប្លែករបស់ខ្ញុំម្ចាស់ មិនងាយនឹងរកបានទេ ខ្ញុំម្ចាស់មិនពោលឥឡូវនេះទេ ពួកព្រានព្រៃរបស់ព្រះអង្គដែលជាអ្នកឈ្នះសង្គ្រាម មានប្រមាណប៉ុណ្ណា សូមទ្រង់ឲ្យព្រានព្រៃនោះទាំងអស់មកប្រជុំគ្នា ខ្ញុំម្ចាស់នឹងពោលក្នុងកណ្តាលពួកព្រានទាំងនោះ ដូច្នេះកាលនឹងសម្តែងសេចក្តីនោះ ទើបព្រះនាងត្រាស់គាថាបន្ទាប់ថា

**លុទ្ធា ទេវ សមាយន្តុ, យេ កេចិ វិជិតេ តវ;**
**ឯតេសំ អហាមក្ខិស្សំ, យាទិសោ មម ទោហឡោ។**

*បពិត្រព្រះសម្មតិទេព សូមឲ្យព្រានទាំងឡាយ ដែលមាននៅក្នុងដែនព្រះអង្គ មកប្រជុំគ្នា ខ្ញុំម្ចាស់នឹងប្រាប់នូវចំណង់ប្លែករបស់ខ្ញុំម្ចាស់ ដល់ព្រានទាំងឡាយនុ៎ះ ។*

ព្រះរាជាទទួលថា ល្អ ហើយទ្រង់ចេញពីបន្ទប់ដ៏មានសិរី ត្រាស់បញ្ជាអាមាត្យទាំងឡាយថា ពួកព្រានទាំងឡាយណាក្នុងដែនកាសិករដ្ឋដែលមានប្រមាណ ៣០០ យោជន៍ អ្នកទាំងឡាយចូរវាយស្គរ ឲ្យពួកព្រានទាំងនោះមកប្រជុំគ្នា ។ ពួកអាមាត្យក៏បានធ្វើយ៉ាងនោះ ។ មិនយូរប៉ុន្មាន ពួកព្រានដែលនៅក្នុងដែនកាសិរដ្ឋ កាន់យកបណ្ណាការតាមកម្លាំង មកហើយ ឲ្យគេក្រាបទូលព្រះរាជានូវការមករបស់ខ្លួន ។ ព្រានទាំងអស់នោះមានប្រមាណ ៦

មុឺនទាក់ ។ ព្រះរាជាដឹងការមករបស់ព្រានហើយ ទ្រង់បិតនៅជិត**វាតបាន** (បង្អួច) លើកដៃចង្អុល កាលនឹងប្រាប់ការមករបស់ពួកព្រានដល់ព្រះទេវី ទើបត្រាស់ថា

**ឥមេ តេ លុទ្ទកា ទេវិ, កតហត្ថា វិសារទា;**
**វនញ្ញា ច មិគញ្ញា ច, មមត្ថេ ចត្តជីវិតា។**

ម្នាលនាងទេវី ពួកព្រានព្រៃទាំងនេះ ជាអ្នកមានថ្វីដៃ ជាអ្នកក្លៀវក្លា ស្គាល់ព្រៃផង ស្គាល់ម្រឹគផង សឹងតែជាអ្នកស៊ូលះបង់នូវជីវិត ក្នុងប្រយោជន៍របស់យើង ។

ព្រះទេវីស្តាប់ពាក្យនោះហើយ កាលនឹងប្រាប់ពួកព្រានទាំងនោះ ទើបត្រាស់គាថាមួយទៀតថា

**លុទ្ទបុត្តា និសាមេថ, យាវន្តេត្ថ សមាគតា;**
**ឆព្ពិសាណំ គជំ សេតំ, អទ្ទសំ សុបិនេ អហំ;**
**តស្ស ទន្តេហិ មេ អត្ថោ, អលាភេ នត្ថិ ជីវិតំ។**

ម្នាលលុទ្ទបុត្រទាំងឡាយ អ្នកទាំងឡាយ ទាំងប៉ុន្មាននាក់ មកប្រជុំគ្នាក្នុងទីនេះ ចូរ ស្តាប់ (ពាក្យរបស់យើងចុះ) យើងបានយល់សប្តិឃើញដំរីស មានភ្លុកប្រាំមួយពណ៌ យើងត្រូវការដោយភ្លុកដំរីសនោះ ជីវិត (របស់យើង) នឹងមិនមាន ព្រោះការមិនមានភ្លុកនោះ ។

ពួកលុទ្ទបុត្តស្តាប់ពាក្យនោះ នាំគ្នាពោលថា

**នោ បិតូនំ ន បិតាមហានំ, ទិដ្ឋោ សុតោ កុញ្ជរោ ឆព្ពិសាណោ;**
**យមទ្ទសា សុបិនេ រាជបុត្តី, អក្ខាហិ នោ យាទិសោ ហត្ថិនាគោ។**

*បិតានិងជីតារបស់ទូលព្រះបង្គំជាខ្ញុំ មិនដែលឃើញ មិនដែលឮ នូវដំរីមានភ្លុក ( ពណ៌) ប្រាំមួយ ដែលព្រះរាជបុត្រីបានទ្រង់ព្រះសុបិនឃើញនោះទេ សូមព្រះនាងទ្រង់ សវនីយ៍ ប្រាប់នូវដំរីដ៏ប្រសើរប្រាកដដូច្នោះ ដល់ពួកទូលព្រះបង្គំជាខ្ញុំចុះ ។*

*ពួកកូនព្រានពោលថា បពិត្រព្រះទេវី ដំរីដែលមានសភាពបែបនោះ បិតានិងជីតារបស់ទូលព្រះបង្គំ មិនធ្លាប់ឃើញទេ ចាំបាច់ពោលទៅថ្វីដល់ទូលព្រះបង្គំជាខ្ញុំនោះ ព្រោះហេតុនោះ ដំរីដែលព្រះនាងយល់ព្រះសុបិនឃើញយ៉ាងណា សូមព្រះនាងប្រាប់ដំរីនោះដោយអំណាចនៃលក្ខណៈ ដែលព្រះនាងបានឃើញ ដល់ទូលព្រះបង្គំជាខ្ញុំផង ។*

*ពួកលុទ្ទបុត្តដទៃពោលគាថាបន្ទាប់ថា*

**ទិសា ចតស្សោ វិទិសា ចតស្សោ, ឧទ្ធំ អធោ ទស ទិសា ឥមាយោ;**
**កតមំ ទិសំ តិដ្ឋតិ ជាតរាជា, យមទ្ទសា សុបិនេ ឆព្ពិសាណំ។**

***បណ្តាទិសទាំង ១០ នេះគឺ ទិសធំ ៤ ទិសតូច ៤ ទិសខាងលើ ១ ទិសខាងក្រោម ១ តើព្រះរាជបុត្រីទ្រង់ព្រះសុបិនឃើញដំរីដ៏ប្រសើរ មានភ្លុកប្រាំមួយពណ៌ បិតនៅក្នុងទិសណា ។***

*កាលពួកព្រានពោលយ៉ាងនេះហើយ ព្រះទេវីសម្លឹងមើលលុទ្ទបុត្តទាំងអស់ បានឃើញព្រានម្នាក់ឈ្មោះ **សោនុត្តរ** ដែលធ្លាប់ចងពៀរនឹងព្រះមហាសត្វ ប្រាកដជាព្រានខ្លាំងពូកែជាងកូនព្រានទាំងអស់ ដែលមានរូបរាងអាក្រក់គួរឲ្យខ្ពើម មានជើងត្រដាង មានស្មងដូចពំនូតបាយ មានជង្គង់ធំ មានធ្អឹងជំនីរធំ មានពុកមាត់ក្រាស់ មានចង្កូមក្រហម មានភ្នែកលឿង ហើយត្រិះរិះថា បុរសនេះទើបអាចធ្វើតាមពាក្យយើងបាន ដូច្នេះទើបក្រាបទូលសូមរាជានុញ្ញាត នាំព្រាននោះ ឡើងទៅខាងលើប្រាសាទជាន់ទី ៧ បើកសីហបញ្ជរទិសឧត្តរ លាតព្រះហស្តចង្អុលទៅព្រៃហិមពាន្តទិសខាងជើង ហើយត្រាស់ ៤ គាថាថា*

**ឥតោ ឧជុំ ឧត្តរិយំ ទិសាយំ, អតិក្កម្ម សោ សត្ត គិរី ព្រហ្មាន្តេ;**

សុវណ្ណបស្សោ នាម គិរី ឧឡារោ, សុបុប្ផិតោ កិម្បុរិសានុចិណ្ណោ។

អ្នកចេញអំពីទីនេះ ដើរត្រង់ទៅទិសខាងជើង រំលងភ្នំធំទាំង ៧ ទៅ នឹងឃើញភ្នំធំលើសលុបមួយឈ្មោះសុវណ្ណបស្សៈ ជាភ្នំមានផ្កាឈើរីកព្រោងព្រាត កុះករដោយពួកកិន្នរ ។

អារុយ្ហ សេលំ ភវនំ កិន្នរានំ, ឱលោកយ បព្ពតបាទមូលំ;
អថ ទក្ខសី មេឃសមានវណ្ណំ, និគ្រោធរាជំ អដ្ឋសហស្សបាទំ។

អ្នកចូរឡើងកាន់ភ្នំ ជាលំនៅរបស់ពួកកិន្នរនោះ ហើយរមិលមើលនូវទីជិតនៃជើងភ្នំ គ្រានោះ អ្នកនឹងឃើញនូវស្តេចជ្រៃមួយដើម មានឫស ៨០០០ មានពណ៌ប្រាកដស្មើមេឃ ។

តត្ថច្ឆតី កុញ្ជរោ ឆព្ពិសាណោ, សព្ពសេតោ ទុប្បសហោ បរេភិ;
រក្ខន្តិ នំ អដ្ឋសហស្សនាគា, ឦសាទន្តា វាតជវប្បហារិនោ។

ឯស្តេចដំរីមានភ្លុកប្រាំមួយពណ៌ មានខ្លួនសសុទ្ធ ដែលពួកដំរីដទៃគ្រប់សង្កត់បានដោយក្រ តែងនៅជិតដើមជ្រៃនោះ ដំរីទាំងឡាយ ៨០០០ មានភ្លុកដូចចន្ទោលរទេះ មានប្រក្រតីទៅប្រហារដោយសន្ទុះ ដូចជាខ្យល់ តែងរក្សានូវស្តេចដំរីនោះ ។

តិដ្ឋន្តិ តេ តុមូលំ បស្សសន្តា, កុប្បន្តិ វាតស្សបិ ឦរិតស្ស;
មនុស្សភូតំ បន តត្ថ ទិស្វា, ភស្មំ ករេយ្យុំ នាស្ស រជោបិ តស្ស។

ពួកដំរីទាំង ៨០០០ នោះ ឈរដកដង្ហើមខ្លាំងៗ តែងក្រោធចំពោះវត្ថុ សូម្បីដែលខ្យល់បក់ត្រូវហើយ មួយទៀត បើវាឃើញមនុស្សក្នុងទីនោះហើយ ក៏ធ្វើឲ្យទៅជាផេះ សូម្បីតែធូលី គឺ ផេះរបស់មនុស្សនោះ ក៏មិនឲ្យមានឡើយ ។

ព្រានសោនុត្តរនោះស្តាប់ពាក្យនោះហើយ ភ័យខ្លាចចំពោះមរណៈ ពោលថា

ពហូ ហិមេ រាជកុលម្ហិ សន្តិ, បិឡន្ធនា ជាតរូបស្ស ទេវិ;
មុត្តា មណី វេឡុរិយាមយា ច, កាំ កាហសិ ឥន្ទបិឡន្ធនេន;
មាវេតុកាមា កុញ្ជរាំ ឆព្ពិសាណាំ, ឧទាហុ ឃាតេស្សសិ លុទ្ទបុត្តេ។

*បពិត្រព្រះនាងទេវី គ្រឿងប្រដាប់ទាំងឡាយដ៏ច្រើន ដែលគេធ្វើដោយមាសក្តី កែវមុក្តាក្តី កែវមណីក្តី គ្រឿងប្រដាប់ជាវិការៈនៃកែវពៃទូរ្យក្តី សឹងមានក្នុងរាជត្រកូល ចុះព្រះនាងមានប្រាថ្នានឹងសម្លាប់ដំរីមានភ្លុក (ពណ៌) ប្រាំមួយ យកមកធ្វើគ្រឿងប្រដាប់ជាវិការៈនៃភ្លុកឬ ឬក៏ព្រះនាងចង់សម្លាប់ពួកលុទ្ទបុត្រ (កូនព្រាន) ។*

*លំដាប់នោះ ព្រះទេវីពោលគាថាថា*

សា ឥស្សិតា ទុក្ខិតា ចស្មិ លុទ្ទ, ឧទ្ធញ្ច សុស្សាមិ អនុស្សរន្តី;
ករោហិ មេ លុទ្ទក ឯតមត្ថំ, ទស្សាមិ តេ គាមវរានិ បញ្ច។

*ម្នាលព្រានព្រៃ (មិនមែនដូច្នោះទេ) យើងជាស្រីច្រណែនផង ជាស្រីដល់នូវសេចក្តីទុក្ខផង យើងរឭកឃើញ (នូវពៀរ) ក្នុងខាងដើម (ដែលដំរីនោះធ្វើហើយដល់យើង) ផង បានជាបេះតែស្គាំងស្គម ម្នាលព្រានព្រៃ អ្នកចូរធ្វើសេចក្តីនេះដល់យើងចុះ យើងនឹងឲ្យស្រុកសួយ ៥ ដល់អ្នក ។*

*ពាក្យថា **យើងនឹងឲ្យស្រុកសួយ ៥ ដល់អ្នក** សេចក្តីថា នៅពេលសេចក្តីប្រាថ្នារបស់យើងបានសម្រេច យើងនឹងឲ្យស្រុកសួយដ៏ប្រសើរ ៥ ដែលរកប្រាក់ចំណូលបាន ១ សែន ក្នុង ១ ឆ្នាំៗ ដល់អ្នក ។*

*ព្រះទេវីពោលយ៉ាងនេះហើយ ក៏លួងលោមព្រានថា នែលុទ្ទបុត្តសម្លាញ់ ក្នុងជាតិមុនយើងបានថ្វាយទានដល់ព្រះបច្ចេកពុទ្ធ ហើយតាំងសេចក្តីប្រាថ្នាថា សូមឲ្យយើងបានជា*

មនុស្សអាចឲ្យអ្នកដទៃសម្លាប់ដំរីឆទ្ទន្តនោះ យកភ្លុកទាំងគូឲ្យបាន គឺមិនមែនជាការយល់សប្តិទេ សេចក្តីប្រាថ្នារបស់យើងនឹងសម្រេច អ្នកចូរទៅចុះ កុំខ្លាចឡើយ ដូច្នេះហើយ ក៏បញ្ជូនព្រាននោះទៅ ។ សោនុត្តរព្រានទទួលពាក្យព្រះនាងថា ល្អ ហើយពោលថា សូមព្រះនាងធ្វើគ្រឿងសម្គាល់ឲ្យប្រាកដ ចូរប្រាប់ទីលំនៅរបស់ដំរីនោះ ដូច្នេះកាលនឹងសួរ ទើបពោលគាថានេះថា

**កត្ថច្ឆតី កត្ថ មុបេតិ ឋានំ, វីថិស្ស កា ន្ហានគតស្ស ហោតិ;**
**កថញ្ហិ សោ ន្ហាយតិ នាគរាជា, កថំ វិជានេមុ គតឹ គជស្ស។**

ដំរីឆទ្ទន្តនោះ តែងនៅត្រង់ទីណា តែងចូលទៅឈរក្នុងកន្លែងណា ផ្លូវដូចម្តេចដែលដំរីឆទ្ទន្តចុះទៅងូតទឹក ស្តេចដំរីឆទ្ទន្តនោះ ងូតទឹកតើដូចម្តេច យើងខ្ញុំធ្វើម្តេច នឹងដឹងដំណើរនៃដំរីនោះបាន ។

លំដាប់នោះ ព្រះនាងទេវីក៏ពិចារណាញាណ ដែលជាគ្រឿងរលឹកជាតិ កាលនឹងប្រាប់ ទើបត្រាស់ ២ គាថាថា

**តត្ថេវ សា ពោក្ខរណី អទូរេ, រម្មា សុតិត្ថា ច មហោទិកា ច;**
**សម្បុប្ផិតា ភមរគណានុចិណ្ណា, ឯត្ថ ហិ សោ ន្ហាយតិ នាគរាជា។**

ត្រង់កន្លែងដែលដំរីនៅនោះ មានស្រះបោក្ខរណីនៅជិត ជាស្រះគួររីករាយផង មានកំពង់ទឹកដ៏ល្អផង មានទឹកដ៏ច្រើនផង (មានកុមុទ ឧប្បល និងឈូក) មានផ្ការីកស្គុះស្គាយផង ដេរដាសដោយពួកភមរជាតិផង ស្តេចដំរីដ៏ប្រសើរនោះ តែងងូតទឹកក្នុងស្រះនុ៎ះឯង ។

**សីសំ នហាតុប្បលមាលភារី, សព្វសេតោ បុណ្ឌរីកត្តចង្គី;**
**អាមោទមានោ គច្ឆតិ សន្និកេតំ, បុរក្ខត្វា មហេសឹ សព្វភទ្ទំ។**

***ដំរីឆទ្ទន្តនោះ ជាដំរីសសុទ្ធ មានស្បែកនិងអវយវៈស ដូចផ្កាឈូកស លាងជម្រះនូវក្បាលរួចហើយ ក៏ទ្រទ្រង់នូវផ្កាឧប្បលជាដើម ត្រេកអរ រីករាយពន់ពេក ក៏ឲ្យមេដំរីជាមហេសីឈ្មោះនាងសព្វកទ្ទា ដើរពីខាងមុខ ហើយដើរសំដៅទៅកាន់ទីកន្លែងនៅរបស់ខ្លួន ។***

*ពាក្យថា **ឲ្យមេដំរីជាមហេសីឈ្មោះនាងសព្វកទ្ទាដើរពីខាងមុខ** សេចក្តីថា ដំរីឆទ្ទន្តនោះធ្វើមហេសីឈ្មោះសព្វកទ្ទា ឲ្យនៅខាងមុខ ឡោមព័ទ្ធដោយដំរី ៨ ពាន់ ដើរទៅលំនៅរបស់ខ្លួន ។*

*ព្រានសោនុត្តរស្តាប់ពាក្យនោះហើយ ទទួលថា ល្អហើយព្រះនាង ខ្ញុំនឹងសម្លាប់ដំរីនោះ ហើយនាំយកភ្លុកដំរីនោះមក ។ គ្រានោះ ព្រះនាងទេវីមានព្រះទ័យរីករាយ ប្រទានទ្រព្យ ១០០០ ដល់ព្រាន ហើយបង្គាប់ថា អ្នកចូរទៅផ្ទះសិនចុះ ៧ ថ្ងៃទៀត សឹមទៅទីនោះ ដូច្នេះហើយ ក៏បញ្ជូនព្រាននោះទៅ រួចឲ្យគេហៅជាងដែកមកបង្គាប់ថា នៃអ្នក យើងត្រូវការកាំបិត ពូថៅ ចប ពន្លាក ញញួរ កាំបិតកាត់គុម្ពព្រៃឫស្សី កន្ត្រៃ កណ្តៀវច្រូតស្មៅ ដាវ ដំបងដែក រណារ ដែកតម្លក់មុខបី ក្រចាប់ដែក អ្នកចូរប្រញាប់ធ្វើរបស់ទាំងអស់ ហើយនាំមកឲ្យយើង ។ រួចព្រះទេវីបង្គាប់ឲ្យជាងស្បែកមកគាល់ ទ្រង់បញ្ជាថា នៃអ្នក អ្នកគួរនឹងធ្វើស្បោងស្បែក សម្រាប់ដាក់សម្ភារៈធ្ងន់ ប្រមាណ ១ កុម្ភៈ (ឈ្មោះជាតួលេខមាត្រាវង្វាល់ ស្មើនឹង ១០ អម្ពណៈ) ឲ្យយើង ហើយយើងត្រូវការខ្សែស្បែក ខ្សែរឹត ស្រោមដៃ ស្បែកជើង និងឆត្រស្បែក អ្នកចូរធ្វើរបស់ទាំងនេះ ឲ្យយើងជាប្រញាប់ ។*

*សូម្បីជាងទាំងពីរក៏បានធ្វើរបស់ទាំងអស់នោះយ៉ាងប្រញាប់ ហើយនាំមកថ្វាយ ។ ព្រះនាងចាត់ចែងរៀបចំស្បៀងដល់ព្រាននោះ ចាប់តាំងពីឈើពំនួតភ្លើងជាដើម ព្រះនាងធ្វើឧបករណ៍គ្រប់យ៉ាង និងស្បៀងមានសដូវជាដើម ដាក់ក្នុងស្បោង គ្រឿងឧបករណ៍ និងស្បៀងទាំងអស់នោះ មានទម្ងន់ប្រមាណ ១ កុម្ភៈ ។*

ចំណែកព្រានសោនុត្តរត្រៀមខ្លួនស្រេចហើយ ក្នុងថ្ងៃទី ៧ ក៏មកគាល់ ថ្វាយបង្គំព្រះរាជទេវី ។ លំដាប់នោះ ព្រះនាងទេវីពោលនឹងនាយព្រានថា នែសម្លាញ់ គ្រឿងឧបករណ៍គ្រប់យ៉ាងរបស់អ្នក រៀបចំស្រេចបាច់អស់ហើយ អ្នកចូរសាកល្បងលើកស្នោងនេះសិនមើល៍ ។ នាយព្រានសោនុត្តរនោះ ជាមនុស្សមានកម្លាំងច្រើន ទ្រទ្រង់នូវកម្លាំងស្មើនឹងដំរី ៥ ព្រោះហេតុនោះ ទើបគេចាប់លើកស្នោងឡើងដូចជាស្នោងម្ជុល ហើយស្ពាយនឹងស្មា ឈរធ្វើព្រងើយ ហាក់ដូចជាមានដៃទទេ ។ ព្រះនាងសុភទ្ទា បានប្រទានស្បៀងអាហារ ដល់កូននិងប្រពន្ធរបស់ព្រាននោះ រួចក្រាបទូលព្រះរាជាឲ្យបញ្ជូនសោនុត្តរព្រានទៅ ។

ព្រានសោនុត្តរនោះ ថ្វាយបង្គំព្រះរាជានិងព្រះទេវី រួចចុះចាករាជានិវេសន៍ ឡើងលើរថ ចេញពីព្រះនគរ ដោយបរិវារជាច្រើន ឆ្លងកាត់ស្រុក និគម និងជនបទ តាមលំដាប់ ដល់បច្ចន្តជនបទ ទើបឲ្យពួកអ្នកស្រុកត្រឡប់វិលវិញ ។ ព្រានសោនុត្តរដើរចូលព្រៃទៅជាមួយនឹងអ្នកស្រុកជាយដែន រហូតដល់ផុតដែនដីមនុស្ស ទើបឲ្យពួកមនុស្សជាយដែនត្រឡប់ទាំងអស់ ហើយដើរទៅតែម្នាក់ឯង ។

នាយព្រានដើរចូលព្រៃ អស់ ៣០ យោជន៍ ដោយឆ្លងកាត់ព្រៃស្អុក ១៨ កន្លែង គឺព្រៃស្បាត ៦ មុនដំបូងព្រៃស្បូវភ្លាំង ព្រៃស្មៅត្រែង ព្រៃស្មៅធម្មតា ព្រៃតុលសិ ព្រៃសរៈ ព្រៃតិរិវច្ឆៈនិងព្រៃទាំងនេះទៀត គឺព្រៃគុម្ពឫស្សីមានបន្លា ព្រៃផ្តៅ ព្រៃរពាក់ ព្រៃបបុស ព្រៃក្រាស់ប្រាកដដូចព្រៃគ្រាប់ព្រួញសូម្បីតែពស់ក៏មិនអាចនឹងលូនទៅបាន ព្រៃដើមឈើ ព្រៃឫស្សី ព្រៃគុម្ពឫស្សីសូម្បីដទៃទៀត ព្រៃភក់ ព្រៃទឹក និងព្រៃភ្នំ ដោយលំដាប់ ។ ព្រានយកកណ្តៀវច្រូតស្បូវភ្លាំងជាដើម យកកាំបិតកាប់គុម្ពព្រៃបន្លាជាដើម យកពូថៅកាប់ដើមឈើ យកពន្លាកចោះដើមឈើធំ កាលធ្វើផ្លូវ ក៏កាប់ឫស្សីធ្វើបង្អោង ឡើងទៅលើគុម្ពឫស្សី ហើយកាប់ឫស្សីដទៃទៀត ឲ្យឫស្សីដួលលើគុម្ពឫស្សីដទៃ រួចដើរទៅដោយគុម្ពឫស្សី ។ កាលដល់ទីដែលមានភក់ក៏ក្រាលក្តារឈើស្ងួត ហើយដើរទៅ និងក្រាលក្តារដទៃ លើកឈើមុនឡើង សម្រាប់ដាក់ទៅខាងមុខ ឆ្លងទីដែលមានភក់បានហើយ ក៏ដល់ទីដែលមានទឹក ក៏ធ្វើក្បូនឆ្លងទៅ ហើយឈរ

នៅត្រង់ជើងភ្នំ នាយព្រានយកខ្សែចងដែកតម្លក់មុខបី បោះឡើងទៅឲ្យជាប់នៅនឹងភ្នំ ហើយតោងឡើង តាមខ្សែស្បែកខាងលើ ដៃឆ្វេងតោងខ្សែ ដៃស្ដាំកាន់ដែកដែលមានមុខមុតដូចពេជ្រ កាប់ថ្មភ្នំស្រេចហើយ ទើបឈរនៅទីនោះ ហើយកន្ត្រាក់ដែកតម្លក់មុខបី បោះទៅខាងលើទៀត ធ្វើទំនងនេះឯងច្រើនដង រហូតឡើងទៅដល់កំពូលភ្នំ ។ កាលដែលចុះពីភ្នំវិញ ក៏ធ្វើទំនងនោះដែរ មុនដំបូង បោះបង្គោលនៅលើកំពូលភ្នំ ចងខ្សែស្បែករុំព័ទ្ធនឹងបង្គោល អង្គុយខាងក្នុងកន្ទ្រង់ ទម្លាក់ខ្សែ ដោយអាការដូចពីងពាងបញ្ចេញសរសៃ ។ អាចារ្យពួកខ្លះបានពោលថា នាយព្រានសោនុត្តរ ចុះអំពីភ្នំដោយឆត្រស្បែក ដូចបក្សី ។

ព្រះសាស្ដា កាលនឹងធ្វើឲ្យជាក់ច្បាស់នូវដំណើរ ដែលព្រានសោនុត្តរកាន់យកព្រះសរនីយ៍របស់ព្រះនាងសុភទ្ទាយ៉ាងនេះ ហើយចេញចាកព្រះនគរ ឆ្លងកាត់ព្រៃស្ដុក ១៧ កន្ទ្វែង រហូតដល់ព្រៃភ្នំ ហើយឆ្លងភ្នំទាំង ៦ និងឡើងលើកំពូលភ្នំសុវណ្ណបស្សៈ ព្រះអង្គទើបត្រាស់ថា

តតោ ច សោ ឧគ្គហេត្វាន វាក់រំ, អាទាយ ត្វាណិញ្ច ជនុញ្ច លុទ្ធោ;
វិតុរិយតិ សត្ត គិរី ព្រហន្តេ, សុវណ្ណបស្សំ ជាម គិរឹ ឧឡារំ។

ព្រានព្រៃនោះ បានរៀនពាក្យក្នុងទីនោះហើយ ក៏ចាប់យកនូវបំពង់ព្រួញ និងធ្នូ (ដើរវំលង) ភ្នំធំទាំង ៧ ក៏ពិចារណាមើលទៅ (ឃើញ) ភ្នំធំខ្ពស់មួយ ឈ្មោះសុវណ្ណបស្សៈ ។

អារុយ្ហ សេលំ ភវនំ កិន្នរានំ, ឱលោកយី បព្ពតបាទមូលំ;
តត្ថទ្ទសា មេឃសមានវណ្ណំ, និគ្រោធរាជំ អដ្ឋសហស្សបាទំ។

ព្រានព្រៃបានឡើងទៅកាន់ភ្នំ ជាកន្ទ្វែងនៅនៃពួកកិន្នរ ក៏រមិលមើលនូវទីជិតនៃជើងភ្នំ បានឃើញស្ដេចជ្រៃធំមួយដើម មានសម្បុរប្រាកដស្មើដោយមេឃ មានឫស ៨០០០ ជិត ជើងភ្នំនោះ ។

តត្ថទ្ទសា កុញ្ជរំ ឆព្ពិសាណំ, សព្ពសេតំ ទុប្បសហំ បរេភិ;
រក្ខន្តិ ធំ អដ្ឋសហស្សជាគា, ឦសាទន្តា វាតជវប្បហារិជោ។

*បានឃើញដំរីមានភ្លុក ៦ ពណ៌ ជាដំរីសសុទ្ធ ដែលពួកដំរីដទៃគ្របសង្កត់បានដោយក្រ នៅក្រោមដើមជ្រៃនោះ ពួកដំរីទាំង ៨០០០ មានភ្លុកង ដូចជាចន្ទោលរថ មានប្រក្រតីទៅប្រហារពួកដំរីបច្ចាមិត្ត ដោយសន្ទុះដ៏លឿនដូចជាខ្យល់ តែងរក្សានូវស្តេចដំរីនោះ ។*

តត្ថទ្ទសា ទោក្ខរណឹ អទូរេ, រម្មំ សុតិត្ថញ្ច មហោទិកញ្ច;
សម្បុប្ផិតំ ភមរគណានុចិណ្ណំ, យត្ថ ហិ សោ ឆ្ហាយតិ ជាគរាជា។

*បានឃើញស្រះបោក្ខរណី នៅជិតដើមជ្រៃនោះ ជាទីគួររីករាយ មានកំពង់ទឹកដ៏ល្អផង មានទឹកដ៏ច្រើនផង (មានផ្កាកុមុទ ឧប្បល និងឈូក) រីកស្គុះស្គាយផង ដេរដាសដោយពួកភមរជាតិផង ជាទីសម្រាប់ងូត របស់ស្តេចដំរីដ៏ប្រសើរនោះ ។*

ទិស្វាឆ ជាគស្ស គតឹ ឋិតិញ្ច, វីជិស្សយា ឆ្ឋានគតស្ស ហោតិ;
ឱចាតមាគច្ឆិ អឆរិយរូបោ, បយោជិតោ ចិត្តវសាឆុគាយ។

*បានឃើញនូវការដើរទៅ និងការឈរនៅ នៃដំរីដ៏ប្រសើរផង ឃើញផ្លូវ របស់ដំរីដ៏ប្រសើរនោះទៅងូតទឹកផង ព្រានព្រៃជាអនរិយជន បានប្រកប (កិច្ចការស្រេច) ដោយការលុះក្នុងអំណាចនៃចិត្ត ក៏បានជីករណ្តៅ ។*

*ពាក្យថា **បានឃើញនូវការដើរទៅ** សេចក្តីថា ក្នុងពេលដែលដំរីទាំងឡាយទៅហើយ នាយព្រានក៏បានចុះអំពីសុវណ្ណបស្សបព៌ត ពាក់ស្រោមដៃស្រោមជើង ពិចារណាត្រួតមើល ទីដែលស្តេចដំរីទៅ និងទីនៅជាប់ជានិច្ច បានឃើញទាំងអស់ថា ស្តេចដំរីទៅដោយផ្លូវនេះ មុជទឹកក្នុងទីនេះ មុជហើយឡើងមកដោយផ្លូវនេះ មកឈរត្រង់កន្លែងនេះ ដូច្នេះហើយ*

ព្រោះភាពជាអ្នកមិនមានហិរិ ព្រានជាអនរិយជន ត្រូវព្រះនាងសុភទ្ទា ជាអ្នកលុះក្នុងអំណាចនៃចិត្តក្រោធ ប្រើមក ព្រោះហេតុនោះ ព្រានទើបជីករណ្តៅ ។

ក្នុងរឿងនោះ មានការពោលតាមលំដាប់ថា ៖

បានឮមកថា ព្រានសោនុត្តរមកដល់លំនៅព្រះមហាសត្វ ដោយប្រើពេលអស់ ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ កាលពិចារណាទីនៅរបស់ព្រះមហាសត្វ ដូចន័យដែលពោលហើយ ព្រាននោះកំណត់ថា យើងនឹងជីករណ្តៅក្នុងទីនេះ បិតនៅក្នុងទីរណ្តៅនោះ បាញ់ស្តេចដំរីដោយព្រួញពិសឲ្យស្លាប់ ដូច្នេះទើបចូលទៅកាន់ព្រៃ កាត់ដើមឈើ ដើម្បីធ្វើសសរជាដើម រៀបចំទព្វសម្ភារៈទុក ក្នុងកាលដែលដំរីទាំងឡាយទៅមុជទឹក ព្រានក៏យកចបធំមកជីករណ្តៅ ៤ ជ្រុងត្រង់ទីនៅនៃស្តេចដំរី រួចកាយដី យកទឹកមកស្រោច ហាក់ដូចជាដាំគ្រាប់ពូជ ដាក់សសរខាងលើត្បាល់ថ្ម ដាក់រនូត ក្រាលផែនក្តារ ចោះប្រហោងប៉ុនកូនសរ រោយសម្រាម និងដីនៅខាងលើ ធ្វើផ្លូវចូលទៅរបស់ខ្លួនដោយចំណែកមួយ កាលធ្វើរណ្តៅរួចហើយ ក្នុងវេលាជិតភ្លឺ ព្រាននោះទទូរក្បាល ដណ្តប់សំពត់កាសាយៈ កាន់ធ្នូនិងព្រួញដែលលាបដោយថ្នាំពិស ចុះទៅនៅក្នុងរណ្តៅ ។

ព្រះសាស្តាកាលនឹងប្រកាសសេចក្តីនោះ ទើបត្រាស់ថា

**១ឍិត្វាន កាសុំ ផលកេហិ ឆាទយិ, អត្តានមោធាយ ធនុញ្ច លុទ្ទោ;**
**បស្សាគតំ បុថុសល្លេន នាគំ, សមប្បយី ទុក្កដកម្មការី។**

ព្រានព្រៃជាអ្នកធ្វើអំពើអាក្រក់ ជីករណ្តៅហើយ គ្របដោយផែនក្តាទាំងឡាយ រួចបញ្ចូលខ្លួននិងធ្នូ (ទៅក្នុងរណ្តៅនោះ) ហើយបាញ់នូវដំរី ដែលដើរមកក្បែរខាង (រណ្តៅរបស់ខ្លួន) ដោយព្រួញដ៏ធ្ងោស ។

**រត្តា ច ជាតោ កោញ្ចមជានិ យោរំ, សព្ពេ ច ជាតា និច្ចធម្មិ យោរប្បំ;**
**តិណាញ្ញា កដ្ឋញ្ញា រណំ គកោ្ដ, ជាវិសុ តេ អដ្ឋ ទិសា សមន្តតោ។**

*ដំរីដ៏ប្រសើរ ត្រូវព្រានព្រៃបាញ់ហើយ ក៏បន្លឺនូវកោញ្ចនាទដ៏ពន្លឹក ពួកដំរីទាំងអស់ ក៏បន្លឺនូវសម្លេងមានសភាពដ៏ពន្លឹក ដំរីទាំងនោះក៏ធ្វើនូវស្មៅ និងមែកឈើឲ្យខ្ទេចខ្ទី ហើយស្ទុះស្ទាទៅទាំង ៨ ទិសជុំវិញ ។*

**វធិស្សមេតន្តិ បរាមសន្តោ, កាសាវមទ្ទក្ខិ ធជំ ឥសីនំ;**
**ទុក្ខេន ផុដ្ឋស្សុទបាទិ សញ្ញា, អរហទ្ធជោ សព្ភិ អវជ្ឈរូបោ។**

*ដំរីដ៏ប្រសើរក៏ចាប់ព្រាននោះ ដោយបំណងថា អញនឹងសម្លាប់ព្រាននុ៎ះ ក៏ឃើញនូវសំពត់កាសាវៈ ដែលជាទង់ជ័យរបស់ពួកឥសី ដំរីដ៏ប្រសើរ ត្រូវសេចក្តីទុក្ខប៉ះពាល់ហើយ ក៏មានសញ្ញាកើតឡើងថា ធម្មតាបុគ្គលប្រើប្រាស់ទង់ជ័យព្រះអរហន្ត មានសភាពដែលសប្បុរសមិនគួរសម្លាប់ ។*

*បានឮមកថា ក្នុងថ្ងៃទី ២ ស្តេចដំរីនោះ មកមុជទឹក ហើយឡើងឈរ នៅលើប្រទេសដែលមានឈ្មោះថា* ***មហាវិសាលមាលកៈ*** *។ លំដាប់នោះ ទឹកបានហូរពីសរីរៈរបស់ស្តេចដំរីហូរស្រក់តាមនាភីប្រទេស ធ្លាក់មកលើសរីរៈរបស់នាយព្រានតាមប្រហោងក្តារ ។ ដោយសញ្ញានោះ នាយព្រានដឹងថា ព្រះមហាសត្វមកឈរពីលើហើយ ក៏យឹតព្រួញដ៏ធំបាញ់ស្តេចដំរីដែលមកឈរខាងលើនោះ ។*

*បានឮមកថា ព្រួញដ៏ថ្លោសនោះចូលតាមនាភីប្រទេស ធ្លុះចូលទៅកាត់តម្រងបស្សាវៈជាដើម បុកទម្លុះដល់សាច់ខ្នង ហើយផ្លាយចេញទៅកាន់អាកាស ហាក់ដូចជាពុះដោយពូថៅ ។ ឈាមហូរចេញតាមមុខរបួស ហាក់ដូចជា ទឹកជ្រលក់ចូរចេញពីឆ្នាំងជ្រលក់ដែល*

បែក ទុក្ខវេទនាដ៏ខ្លាំងក្លាបានកើតឡើង ។ ស្តេចដំរីកាលមិនអាចនឹងអត់សង្កត់ទុក្ខវេទនា ក៏ស្រែកកងរំពងលាន់ឮសន្ធឹកពេញសកលបព៌ត បន្លឺកោញ្ចនាទដ៏ខ្លាំង ៣ ដង ។ ដំរីទាំង ៨០០០ ស្តាប់ឮសំឡេងនោះហើយ ភ័យខ្លាចចំពោះមរណៈ ក៏ធ្វើនូវសំឡេង ស្រែកឡើង គួរញញើត ។ ដំរីទាំងអស់ស្ទុះទៅដោយសំឡេងនោះ បានឃើញដំរីឆទ្ទន្តកំពុងដល់ទុក្ខវេទនា ហើយគិតថា ពួកយើងនឹងចាប់សត្រូវ ដូច្នេះទើបស្ទុះរត់ទៅដោយជុំវិញ បានធ្វើស្មៅនិងកំណាត់ឈើឲ្យបែកខ្ទេច ។

ពាក្យថា **អញនឹងសម្លាប់ព្រាននុ៎ះ** សេចក្តីថា ព្រះពុទ្ធត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ដំរីឆទ្ទន្តនោះ កាលដែលដំរីទាំងឡាយចេញទៅក្នុងទិសទាំងឡាយហើយ និងកាលដែលមេដំរីមហាសុភទ្ទាចូលទៅឈរជិត ស្ទាបអង្អែលហើយលួងលោម ស្តេចដំរីក៏អត់សង្កត់ទុក្ខវេទនា កាលពិចារណាកន្ទែងដែលព្រួញមក ទើបគិតថា បើព្រួញនេះមកពីទិសខាងកើត នឹងត្រូវចូលតាមពោង ហើយធ្លុះចេញទៅតាមកាយខាងក្រោយជាដើម តែព្រួញនេះចូលមកតាមនាភី ហើយចេញទៅកាន់អាកាស ព្រោះហេតុនោះ ពិតជាមានមនុស្សនៅខាងក្រោមបាញ់មក ព្រះមហាសត្វពិចារណាយ៉ាងនេះហើយ បំណងនឹងត្រួតមើលកន្ទែងឈរ ទើបគិតថា អ្នកណានឹងដឹងថា មានអ្វីកើតឡើង យើងគួរនឹងឲ្យនាងមហាសុភទ្ទាចេញសិន ដូច្នេះទើបពោលថា នែនាងដ៏ចម្រើន ដំរី ៨០០០ ស្វែងរកសត្រូវរបស់យើង រត់ទៅទិសទាំងឡាយ ចុះនាងនៅធ្វើអ្វី ក្នុងទីនេះ ។ មេដំរីមហាសុភទ្ទាពោលថា បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់នៅទ្រទ្រង់លួងលោមលោកម្ចាស់ សូមស្តេចដំរីអត់ទោសដល់ខ្ញុំ ដូច្នេះហើយ ធ្វើប្រទក្សិណ ៣ ដង ថ្វាយបង្គំព្រះពោធិសត្វក្នុងទិសទាំង ៤ រួចហោះទៅកាន់អាកាស ។ ស្តេចដំរីយកជើងឈូសកកាយដី បន្ទះក្តារក៏របើកឡើង ។ ព្រះមហាសត្វកាលមើលតាមប្រហោង ឃើញនាយព្រានសោនុត្តរ ហើយញ៉ាំងចិត្តឲ្យកើតឡើងថា យើងនឹងសម្លាប់វា ទើបលូកប្រមោយដែល

មានពណ៌ដូចជាគួងប្រាក់ ចាប់ព្រាននោះ ក៏ឃើញសំពត់កាសាវៈ ដែលជាទង់នៃព្រះពុទ្ធជាឥសី ។ នាយព្រានដាក់សំពត់កាសាវៈក្នុងប្រមោយរបស់ព្រះមហាសត្វ ។ ព្រះពោធិសត្វលើកព្រាននោះ ដាក់នៅខាងមុខ ។ លំដាប់នោះ សញ្ញានេះបានកើតដល់ស្តេចដំរី ដែលកំពុងទទួលសេចក្តីទុក្ខដូច្នេះថា ឈ្មោះថា ទង់ជ័យនៃព្រះអរហន្ត គឺបណ្ឌិតទាំងឡាយមិនគួរទម្លាយឡើយ គួរតែធ្វើសក្ការៈ គោរពតែម្យ៉ាងប៉ុណ្ណោះ ។

ស្តេចដំរីកាលនឹងចរចាជាមួយព្រាននោះ ទើបពោល ២ គាថាថា

អនិក្កសាវោ កាសាវំ, យោ វត្ថំ បរិទហិស្សតិ;
អបេតោ ទមសច្ចេន, ន សោ កាសាវមរហតិ។

បុគ្គលណា មិនទាន់អស់ទឹកចត់គឺកិលេស ជាអ្នកប្រាសចាកការទូន្មាននូវឥន្ទ្រិយនិងវចីសច្ចៈ នឹងស្លៀកដណ្តប់សំពត់កាសាវៈ បុគ្គលនោះមិនគួរស្លៀកដណ្តប់សំពត់កាសាវៈទេ ។

យោ ច វន្តកសាវស្ស, សីលេសុ សុសមាហិតោ;
ឧបេតោ ទមសច្ចេន, ស វេ កាសាវមរហតិ។

ចំណែកបុគ្គលណា ខ្ជាក់ចោលនូវទឹកចត់ គឺកិលេស តាំងមាំក្នុងសីលទាំងឡាយ ជាអ្នកប្រកបដោយការទូន្មាននូវឥន្ទ្រិយនិងវចីសច្ចៈ បុគ្គលនោះឯង ទើបគួរនឹងស្លៀកដណ្តប់សំពត់កាសាវៈ ។

គាថានោះមានសេចក្តីថា នៃលុទ្ទបុត្តសម្លាញ់ បុរសណានៅមានទឹកចត់ គឺរាគៈជាដើម ជាអ្នកប្រាសចាកការទូន្មាននូវឥន្ទ្រិយ និងវចីសច្ចៈ ហើយស្លៀកដណ្តប់សំពត់កាសាវៈ ដែលជ្រលក់ដោយទឹកអម្ចត់ បុរសនោះមិនគួរស្លៀកដណ្តប់សំពត់កាសាវៈ សំពត់កាសាវៈនោះ មិនសមគួរដល់បុរសនោះទេ ។ ចំណែកបុរសណា មានទឹកចត់ខ្ជាក់ចោលហើយ

*សមាទានតាំងស៊ប់ក្នុងសីល បរិបូណ៌ដោយសីលាចារវត្ត បុរសនោះ ទើបឈ្មោះថា សមគួរនឹងស្លៀកដណ្តប់សំពត់កាសាវៈនោះ ។*

*ព្រះមហាសត្វពោលយ៉ាងនេះហើយ ក៏បានញុំាងចិត្តនោះឲ្យរលត់ ហើយសួរថា នៃសម្លាញ់ អ្នកបាញ់យើង ដោយប្រយោជន៍អ្វី ដោយប្រយោជន៍របស់ខ្លួន ឬក៏ប្រកបដោយប្រយោជន៍របស់អ្នកដទៃ ។*

*ព្រះសាស្តាកាលនឹងធ្វើឲ្យជាក់ច្បាស់សេចក្តីនោះ ទើបត្រាស់ថា*

**សមប្បិតោ បុថុសល្លេន ជាគោ, អទុដ្ឋចិត្តោ លុទ្ទកមជ្ឈភាសិ;**
**កិមត្ថយំ កិស្ស វា សម្ម ហេតុ, មមំ វធី កស្ស វាយំ បយោគោ។**

*ដំរីដ៏ប្រសើរ ត្រូវព្រានព្រៃបាញ់ហើយដោយសរដ៏ថ្លោស មិនមានចិត្តប្រទូស្ត បាននិយាយនឹងព្រានព្រៃថា នៃសម្លាញ់ អ្នកត្រូវការអ្វី តើព្រោះអ្វី បានជាអ្នកសម្លាប់យើងម្យ៉ាងទៀត ការប្រកបនេះរបស់បុគ្គលណា ។*

*គ្រានោះ ព្រានកាលនឹងប្រាប់ ទើបពោលគាថាថា*

**កាសិស្ស រញ្ញោ មហេសី ភទន្តេ, សា បូជិតា រាជកុលេ សុភទ្ទា;**
**តំ អទ្ទសា សា ច មមំ អសំសិ, ទន្តេហិ អត្ថោតិ ច មំ អវោចា។**

*បពិត្រដំរីដ៏ចម្រើន ព្រះមហេសីរបស់ស្តេចក្នុងដែនកាសីនោះ ឈ្មោះនាងសុភទ្ទា ដែលគេបូជាហើយក្នុងរាជត្រកូល ព្រះនាងបានឃើញអ្នក ហើយប្រាប់ខ្ញុំ ព្រះនាងក៏មានព្រះសវនីយ៍នឹងខ្ញុំថា យើងត្រូវការដោយភ្លុកទាំងឡាយ ។*

*ស្តេចដំរីស្តាប់ពាក្យនោះហើយ ដឹងថា នេះជាអំពើរបស់នាងចូឡសុភទ្ទា ព្រះមហាសត្វខំអត់សង្កត់នូវទុក្ខវេទនា ហើយពោលថា សេចក្តីត្រូវការដោយភ្លុករបស់យើង រមែងមិន*

មានដល់នាង នាងបញ្ជូនអ្នកមក ដោយសេចក្ដីប្រាថ្នាសម្លាប់យើង ដូច្នេះហើយ កាលនឹងសម្ដែងសេចក្ដីនោះ ទើបពោល ២ គាថាថា

ពហូ ហិមេ ទន្តយុគា ឧឡារា, យេ មេ បិតូនញ្ច បិតាមហានំ;
ជានាតិ សា កោធនា រាជបុត្តី, វធត្ថិកា វេរមការិ ពាលា។

ព្រះរាជបុត្រីនោះ ដឹងថា គូនៃភ្លុកទាំងឡាយរបស់បិតា និងជីតាទាំងឡាយរបស់យើង មានច្រើនណាស់ តែនាងជាស្រីក្រោធ ត្រូវការសម្លាប់ ជាស្រីល្ងង់ ចងពៀរ (នឹងយើង) ។

ឧដ្ឋេហិ ត្វំ លុទ្ទ ខរំ គហេត្វា, ទន្តេ ឥមេ ឆិន្ទ បុរា មរាមិ;
វជ្ជាសិ តំ កោធនំ រាជបុត្តឹ, នាគោ ហតោ ហន្ទ ឥមស្ស ទន្តា។

នែព្រានព្រៃ អ្នកចូរក្រោកឡើង ចាប់នូវរណារ ហើយអារនូវភ្លុកទាំងគូនេះចុះ ទាន់ខ្ញុំមិនទាន់ស្លាប់ អ្នកឯងគប្បីទូលព្រះរាជបុត្រី ដែលមានសេចក្ដីក្រោធនោះថា ដំរីដ៏ប្រសើរ ទូលព្រះបង្គំជាខ្ញុំ បានសម្លាប់ហើយ សូមព្រះនាងទទួលយក នេះជាភ្លុករបស់ដំរីនោះ ។

ព្រានសោនុត្តរស្ដាប់ពាក្យរបស់ដំរីឆទ្ទន្តនោះហើយ ក្រោកចាកទីអង្គុយ កាន់យករណារ ចូលទៅកាន់សម្នាក់ស្ដេចដំរី ដោយគិតថា យើងកាត់ភ្លុក ។ ស្ដេចដំរីមានកម្ពស់ ៨៨ ហត្ថ ឈរនៅដូចជាភ្នំប្រាក់ ព្រោះហេតុនោះ សោនុត្តរព្រានទើបឈោងមិនដល់ភ្លុកស្ដេចដំរីនោះ ។ លំដាប់នោះ ព្រះមហាសត្វបង្អោនកាយ ដេកដាក់ក្បាលចុះក្រោម ។ គ្រានោះ ព្រានព្រៃ ឡើងជាន់ប្រមោយដែលប្រាកដដូចក្បួងប្រាក់ របស់ព្រះមហាសត្វ ឋិតនៅលើពោងស្ដេចដំរី ដែលដូចជាកំពូលភ្នំកៃលាស ហើយយកជង្គង់រុញសាច់ដែលនៅជិតមាត់ ញាត់ចូលទៅខាងក្នុង រួចចុះពីពោងដំរី ស៊កណារចូលទៅក្នុងមាត់ យកដៃទាំងពីរទាញទៅទាញមកយ៉ាងខ្លាំង ។ ទុក្ខវេទនាដ៏ខ្លាំងបានកើតដល់ព្រះមហាសត្វ មាត់ពេញដោយលោហិត ។ នាយព្រានអារចុះអារឡើង ក៏មិនអាចនឹងអារភ្លុកឲ្យដាច់បានឡើយ ។ ពេលនោះ ព្រះមហាសត្វ

ខ្ទាក់លោហិតចេញពីមាត់ អត់សង្កត់ទុក្ខវេទនា សួរព្រានថា នែសម្លាញ់ អ្នកមិនអាចនឹងកាត់ឲ្យដាច់ទេឬ ។ នាយព្រានពោលថា បពិត្រលោកម្ចាស់ ពិតមែនហើយ ។ ព្រះមហាសត្វតាំងសតិ ហើយពោលថា នែសម្លាញ់ បើដូច្នោះ អ្នកចូរលើកប្រមោយរបស់យើង ចូរចាប់ចុងរណារ ព្រោះយើងមិនមានកម្លាំងនឹងលើកប្រមោយដោយខ្លួនឯងបានឡើយ ។ នាយព្រានក៏បានធ្វើយ៉ាងនោះ ។

ព្រះមហាសត្វចាប់រណារដោយប្រមោយ ហើយអារទៅអារមក កាត់ដាច់ភ្លុក ហាក់ដូចដាលំពង់ ។ លំដាប់នោះ ព្រះមហាសត្វប្រាប់ឲ្យនាយព្រាននាំភ្លុកនោះមក កាលនឹងឲ្យភ្លុក ក៏ពោលថា នែលុទ្ទបុត្តសម្លាញ់ យើងកាលឲ្យភ្លុកទាំងនេះដល់អ្នក មិនមែនឲ្យដោយគិតថា ភ្លុកនេះមិនជាទីស្រឡាញ់របស់យើងទេ មិនមែនឲ្យដោយប្រាថ្នាភាពជាព្រះឥន្ទ ភាពជាមារ និងជាព្រហ្មទេ តែសព្វញ្ញុតញ្ញាណនោះឯង ដែលជាទីស្រឡាញ់ដ៏ក្រៃលែង ជាងភ្លុកទាំងឡាយនេះ ដោយរយគុណ ដោយពាន់គុណ ដោយសែនគុណ សូមបុណ្យរបស់យើងនេះចូរជាបច្ច័យ នៃចាក់ធ្លុះ ត្រាស់ដឹងសព្វញ្ញុតញ្ញាណ ដូច្នេះហើយ ព្រះពោធិសត្វបានឲ្យភ្លុកដល់នាយព្រាន រួចសួរថា នែសម្លាញ់ អ្នកមកទីនេះអស់កាលប៉ុន្មាន ? កាលនាយព្រានពោលថា អស់កាល ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ព្រះមហាសត្វពោលថា អ្នកចូរទៅដោយអានុភាពរបស់ភ្លុកនេះ អ្នកនឹងដល់នគរពារាណសីក្នុងរវាង ៧ ថ្ងៃប៉ុណ្ណោះ ដូច្នេះហើយ ស្តេចដំរីធ្វើបរិត្តការពារដល់ព្រាននោះ រួចបញ្ជូនទៅ ។ ព្រះពោធិសត្វបញ្ជូនព្រាននោះទៅហើយ កាលដំរីទាំងឡាយ និងមេដំរីមហាសុភទ្ទាមិនទាន់មក លោកក៏ធ្វើកាលកិរិយាទៅក្នុងពេលនោះឯង ។

ព្រះសាស្តាកាលនឹងប្រកាសសេចក្តីនោះ ទើបត្រាស់ថា

**ឧដ្ឋាយ សោ លុទ្ទោ ខរំ គហេត្វា, ឆេត្វាន ទន្តានិ គជុត្តមស្ស;**
**វគ្គូ សុភេ អប្បដិមេ បថព្យា, អាទាយ បក្កាមិ តតោ ហិ ខិប្បំ។**

*ព្រានព្រៃនោះ គ្រាកឈរឡើង ហើយចាប់រណារ អារនូវភ្លុកដំរីដ៏ប្រសើរ ហើយក៏យកនូវភ្លុកដ៏ល្អស្អាត មិនមានភ្លុកឯទៀតប្រៀបផ្ទឹមបាន លើផែនដី រួចដើរចៀសចេញទៅអំពីទីនោះ យ៉ាងឆាប់ ។*

*កាលព្រាននោះចៀសចេញទៅហើយ ដំរីទាំងឡាយរកបច្ចាមិត្តមិនឃើញ ទើបមក ។*

*ព្រះសាស្តាកាលនឹងប្រកាសសេចក្តីនោះ ទើបត្រាស់ថា*

**ភយដ្ដិតា ជាគវំជេន អដ្ដា, យេ តេ ជាតា អដ្ឋ ទិសា វិជាឱ្យ;**
**អទិស្វាន តោសំ គជបច្ចមិត្តំ, បច្ចាគមុំ យេន សោ ជាគរាជា។**

*ពួកដំរីត្រូវភ័យ (អំពីសេចក្តីស្លាប់) បៀតបៀនហើយ ដល់នូវសេចក្តីទុក្ខព្រួយ ព្រោះគេសម្លាប់នូវដំរីដ៏ប្រសើរ បានស្ទុះទៅ គ្រប់ទិសទាំង ៨ លុះមិនឃើញបុរសជាសត្រូវនឹងដំរី ក៏ត្រឡប់មកកាន់ទី របស់ស្តេចដំរីដ៏ប្រសើរវិញ ។*

*ចំណែកនាងមហាសុភទ្ទាក៏មកជាមួយនឹងដំរីទាំងនោះ ។ សូម្បីដំរីទាំង ៨០០០ នោះ យំស្រែកកន្ទក់កន្ទេញក្នុងទីនោះ ហើយទៅកាន់សម្នាក់ព្រះបច្ចេកពុទ្ធដែលជាកុលុបកៈ រួចពោលថា បពិត្រលោកម្ចាស់* ***បច្ចយទាយក*** *(អ្នកឲ្យបច្ច័យ) របស់លោកម្ចាស់ ត្រូវមុតដោយសរដែលលាបដោយថ្នាំពិស ធ្វើកាលកិរិយាហើយ សូមលោកម្ចាស់ទាំងឡាយមកមើលសពរបស់ស្តេចដំរីនោះ ។ ព្រះបច្ចេកពុទ្ធទាំង ៥០០ អង្គ មកតាមផ្លូវអាកាស ចុះត្រង់កន្លែងដ៏ធំ ។ ក្នុងខណៈនោះ ដំរីកំលោះ ២ យកភ្លុកលើកសរីរៈរបស់ស្តេចដំរី ឲ្យថ្វាយបង្គំព្រះបច្ចេកពុទ្ធ រួចដាក់លើជើងថ្ករ ហើយធ្វើឈាបនកិច្ច ។ ព្រះបច្ចេកពុទ្ធទាំងឡាយ ធ្វើការស្វាធ្យាយធម៌ក្នុងទីបូជាសព រហូតទល់ភ្លឺ ។ ដំរី ៨០០០ នាំគ្នារំលត់ភ្លើង រួចថ្វាយបង្គំ យកទឹកមកស្រោច ធ្វើមេដំរីមហាសុភទ្ទាឲ្យនៅខាងមុខ ទៅកាន់លំនៅរបស់ខ្លួន ។*

*ព្រះសាស្តាកាលប្រកាសសេចក្តីនោះ ទើបត្រាស់ថា*

**តេ តត្ថ កាង្ខិត្វា រោទិត្វាន ជាតា, សីសេ សកេ បំសុកំ ឱកិរិត្វា;**
**អគមំសុ តេ សព្ពេ សកំ និកេតំ, បុរក្ខត្វា មហេសឹ សព្ពភទ្ទំ។**

*ដំរីដ៏ប្រសើរទាំងនោះ កន្ទក់កន្ទេញ ពេទ៍ក្នុងទីនោះ ហើយពោយរាយ នូវអាចម៍ដី លើក្បាលរបស់ខ្លួន ដំរីទាំងអស់នោះ ក៏ឲ្យមេដំរីជាមហេសី ឈ្មោះសព្វសុភទ្ទា ដើរមុខ មកកាន់ទីនៅរបស់ខ្លួន ។*

*ចំណែកសោនុត្តរព្រាននាំយកភ្លុកទាំងពីរ មិនទាន់ដល់ថ្ងៃទី ៧ ផង ក៏មកដល់នគរពារាណសី ។*

*ព្រះសាស្តាកាលប្រកាសសេចក្តីនោះ ទើបត្រាស់ថា*

**អាទាយ ទន្តានិ គជុត្តមស្ស, វគ្គូ សុភេ អប្បដិមេ បថព្យា;**
**សុវណ្ណរាជីហិ សមន្តមោទរេ, សោ លុទ្ទកោ កាសិបុរំ ឧបាគមិ;**
**ឧបនេសិ សោ រាជកញ្ញាយ ទន្តេ, ជាតោ ហតោ ហន្ទ ឥមស្ស ទន្តា។**

*ព្រានព្រៃនោះបាន នាំយកភ្លុកទាំងឡាយនៃដំរីដ៏ប្រសើរ ជាភ្លុកល្អ ស្អាត មិនមានភ្លុកឯទៀតផ្ទឹមបាន លើផែនដី ភ្លឺសព្វដោយរស្មី មានពណ៌ដូចជាមាស ហើយចូលទៅកាន់កាសីបុរី ព្រានព្រៃនោះ ក៏បង្អោននូវភ្លុកទាំងឡាយថ្វាយព្រះរាជកញ្ញាថា ដំរីដ៏ប្រសើរ ទូលព្រះបង្គំជាខ្ញុំសម្លាប់បានហើយ សូមព្រះនាងទទួលយក នេះជាភ្លុកទាំងឡាយនៃដំរីនោះ ។*

*ពាក្យថា **ភ្លឺសព្វដោយរស្មី** សេចក្តីថា កាលភ្លុកនោះបញ្ចេញពន្លឺដោយជុំវិញ ហាក់ដូចជាពណ៌មាសទូទាំងព្រៃសណ្ឌៈទាំងមូល ។ ពាក្យថា **បង្អោននូវភ្លុកទាំងឡាយថ្វាយ** សេចក្តីថា*

សោនុត្តរព្រានបញ្ជូនដំណឹងទូលព្រះទេវីថា ទូលព្រះបង្គំបាននាំភ្លុកទាំងគូ ដែលបញ្ចេញរស្មី ៦ ពណ៌ របស់ដំរីឆទ្ទន្តមកហើយ សូមព្រះនាងឲ្យគេតាក់តែងនគរ និងឲ្យក្រាបទូលព្រះរាជា រួចទើបគាត់ចូលកាន់ព្រះនគរដែលគេតាក់តែង ដូចជាទេវនគរ ហើយឡើងកាន់ប្រាសាទ បង្អោនភ្លុកចូលទៅថ្វាយ និងទូលថា បពិត្រព្រះនាងម្ចាស់ បានឮមកថា ព្រះនាងបានធ្វើនូវទោស ត្រឹមតែបន្តិចបន្តួច ក្នុងព្រះហឫទ័យ (ហើយចងពៀរនឹងស្តេចដំរីណា) ស្តេចដំរីនោះ ទូលព្រះបង្គំសម្លាប់ហើយ សូមព្រះនាងដឹងការស្លាប់របស់ស្តេចដំរីនោះ ហើយចូរទទួលយក នេះជាភ្លុករបស់ស្តេចដំរីនោះ ដូច្នេះហើយ ក៏ថ្វាយភ្លុកដល់ព្រះនាង ។

ព្រះនាងសុភទ្ទា យកប្រដាប់ទ្រធ្វើដោយកែវមណី ទទួលភ្លុក ដែលវិចិត្រដោយឆព្វណ្ណរង្សីរបស់ព្រះមហាសត្វ យកមកដាក់នឹងទ្រូង សម្លឹងមើលភ្លុករបស់ស្វាមីខ្លួនក្នុងភពមុន រលឹកព្រះមហាសត្វថា ព្រានសោនុត្តរយកព្រួញពិស បាញ់សម្លាប់ស្តេចដំរី ដែលមានរូបស្អាតយ៉ាងនេះឲ្យស្លាប់ កាត់ភ្លុកទាំងនេះ នាំមក ដូច្នេះហើយ ព្រះនាងកើតសេចក្តីសោកខ្លាំងមិនអាចនឹងអត់សង្កត់បាន ។ ពេលនោះ ដួងហឫទ័យរបស់ព្រះនាងក៏បែកទៅ ហើយធ្វើកាលកិរិយា ក្នុងថ្ងៃនោះឯង ។

ព្រះសាស្តាកាលប្រកាសសេចក្តីនោះ ទើបត្រាស់ថា

**ទិស្វាន ទន្តានិ គជុត្តមស្ស, ភត្តុប្បិយស្ស បុរិមាយ ជាតិយា;**
**តត្ថេវ តស្សា ហទយំ អផាលិ, តេនេវ សា កាលមកាសិ ពាលា។**

ព្រះរាជកញ្ញានោះ ទតឃើញភ្លុកទាំងឡាយនៃដំរីដ៏ប្រសើរ ដែលធ្លាប់ជាប្តី ជាទីស្រឡាញ់អំពីជាតិមុន ក៏បែកហឫទ័យក្នុងទីនោះឯង ហេតុនោះ ព្រះនាងជាស្រីល្ងង់ បានសោយទិវង្គតទៅ ។

សម្ពោធិបត្តោ ស មហានុភាវោ, សិតំ អកាសី បរិសាយ មជ្ឈេ;
បុច្ឆិំសុ ភិក្ខូ សុវិមុត្តចិត្តា, ជាការណោ ចាតុការោន្តិ ពុទ្ធា។

*ព្រះពុទ្ធព្រះអង្គបានសម្រេចនូវសម្ពោធិញ្ញាណផង មានអានុភាពច្រើនផង បានធ្វើនូវការញញឹម ក្នុងកណ្ដាលពពួកបរិស័ទ ពួកភិក្ខុមានចិត្តរួចស្រឡះ ក៏ក្រាប់បង្គំទូលសួរថា ព្រះពុទ្ធទាំងឡាយ មិនដែលធ្វើនូវការញញឹមឲ្យប្រាកដ ដោយឥតហេតុទេ ។*

យមទ្ទសាថ ទហរឹ កុមារឹ, កាសាយវត្ថំ អនគារិយំ ចរន្តឹ;
សា ខោ តទា រាជកញ្ញា អហោសិ, អហំ តទា ជាគរាជា អហោសឹ។

*អ្នកទាំងឡាយ បានឃើញនាងកុមារីណា នៅជំទង់ ស្លៀកសំពត់កាសាវៈ ជាអ្នកបួស នាងកុមារីនោះ ក្នុងកាលនោះ គឺព្រះរាជកញ្ញា ឯស្ដេចដំរីក្នុងកាលនោះ គឺតថាគតឯង ។*

អាទាយ ទណ្ឌានិ គជុត្តមស្ស, វគ្គូ សុកេ អប្បដិមេ បថព្យា;
យោ លុទ្ទកោ កាសិបុរំ ឧចាគមិ, សោ ខោ តទា ទេវទត្តោ អហោសិ។

*ព្រានព្រៃណា កាន់យកនូវភ្លុកទាំងឡាយនៃដំរីដ៏ប្រសើរ ជាភ្លុកដ៏ល្អស្អាត មិនមានភ្លុកឯទៀតប្រៀបផ្ទឹមបានលើផែនដី ហើយចូលទៅកាន់កាសីបុរី ព្រានព្រៃនោះក្នុងកាលនោះ គឺទេវទត្ត ។*

អជាវស្ចុំ ចិររត្តសំសិតំ, ឧច្ចាវចំ ចរិតមិទំ បុរាណំ;
វីតទ្ទរោ វីតសោកោ វិសល្លោ, សយំ អភិញ្ញាយ អភាសិ ពុទ្ធោ។

*ព្រះពុទ្ធ ព្រះអង្គប្រាសចាកសេចក្ដីក្រវល់ក្រវាយ ប្រាសចាកសេចក្ដីសោក ប្រាសចាកនូវកូនសរគឺរាគៈ បានជ្រាបច្បាស់ដោយព្រះអង្គឯង ហើយទ្រង់សំដែងនូវចរិតខ្ពស់និងទាបអំពីដើមនេះ ដែលអន្ទោលទៅ អស់កាលដ៏យូរ ហាក់ដូចមិនកន្លងថ្ងៃ ។*

**អហំ វោ តេន កាលេន, អហោសឹ តត្ថ ភិក្ខវោ;**
**នាគរាជា តទា ហោមិ, ឯវំ ធារេថ ជាតកំ។**

*ម្នាលភិក្ខុទាំងឡាយ កាលនោះ តថាគតនៅក្នុងទីនោះ កាលនោះតថាគត នៅជា ស្តេចដំរី អ្នកទាំងឡាយ ចូរចាំទុកនូវជាតកយ៉ាងនេះចុះ ។*

*គាថាទាំងឡាយនេះ គឺព្រះធម្មសង្គាហកត្ថេរទាំងឡាយ កាលនឹងសរសើរគុណព្រះទសពល បានសម្តែងទុកហើយ ។*

*មនុស្សទាំងឡាយស្តាប់ព្រះធម្មទេសនានេះហើយ ក៏បានសម្រេចជាព្រះអរិយបុគ្គលមានសោតាបន្នជាដើម ។ ចំណែកភិក្ខុនីក្រមុំនោះ ឃើញច្បាស់អរិយសច្ច ជាខាងក្រោយហើយបានសម្រេចព្រះអរហត្ត ។*

*ឆទ្ទន្តជាតក ចប់ ។*

*( ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក តឹសនិបាត បិដកលេខ ៦០ ទំព័រ ១៧១)*

*ថ្ងៃ អង្គារ ១២ កើត ខែទុតិយាសាឍ ឆ្នាំច សំរិទ្ធិស័ក ប.ស. ១៣៨០ ម.ស. ១៩៤០*

*ថ្ងៃទី ២៤ ខែ កក្កដា ព.ស. ២៥៦២ គ.ស.២០១៨*

*ដោយស.ដ.វ.ថ.*